**អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា**
**កិច្ចសន្ទនាអន្តរកម្មជាមួយក្រុមប្រឹក្សាសិទ្ធិមនុស្ស ថ្ងៃទី ២៧ កញ្ញា ២០១៧**
**សេចក្តីថ្លែងការណ៍បឋម**

**សូមពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងសេចក្តីថ្លែងការណ៍ផ្ទាល់មាត់**

លោកប្រធាន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ខ្ញុំមានកិត្តិយសសូមបង្ហាញរបាយការណ៍លើកទីពីររបស់ខ្ញុំស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំសូមកត់សម្គាល់ការកោតសរសើររបស់ខ្ញុំចំពោះក្រុមប្រឹក្សាដែលបានជ្រើសរើសបន្តអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាសម្រាប់រយៈពេលពីរឆ្នាំទៀត នៅក្នុងសេចក្តីសម្រេចលេខ ៣០/២៣។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាផងដែរចំពោះការគាំទ្រយ៉ាងកក់ក្តៅរបស់ខ្លួនដល់ការងាររបស់ខ្ញុំ ទាំងការចេញលិខិតអញ្ជើញយ៉ាងឆាប់រហ័សដើម្បីឲ្យខ្ញុំអាចធ្វើទស្សនកិច្ចផ្លូវការ និងទាំងរៀបចំជំនួបជាផ្លូវការក្នុងអំឡុងពេលទស្សនកិច្ច។ ខ្ញុំក៏សូមទទួលស្គាល់សេចក្តីថ្លែងការណ៍របស់ ឯកឧត្តម កែវ រ៉េមី ក្នុងឱកាសបើកសម័យប្រជុំក្រុមប្រឹក្សានេះ និងគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រជាបន្តនូវអាណត្តិអ្នករាយការណ៍ពិសេស។

របាយការណ៍របស់ខ្ញុំស្តីពីស្ថានភាពសិទ្ធិមនុស្សរយៈពេលមួយឆ្នាំមុននេះ អាចរកបាននៅលេខ A/HRC/36/61។ ដើម្បីធ្វើឲ្យមានអនុលោមភាពទៅតាមលក្ខខណ្ឌតម្រូវការរបស់អ.ស.ប របាយការណ៍នេះត្រូវសរសេរ និងដាក់ជូនការិយាល័យ OHCHR នៅដើមខែមិថុនា ទោះបីជាវាអាចត្រូវបានដាក់បញ្ចូលនូវបច្ចុប្បន្នភាពសង្ខេបមួយចំនួន បន្ទាប់ពីមានការពិនិត្យឡើងវិញដោយរដ្ឋក៏ដោយ។ នៅក្នុងសេចក្តីថ្លែងការណ៍ដោយផ្ទាល់នេះ ខ្ញុំមានគោលបំណងចម្បងដើម្បីធ្វើបច្ចុប្បន្នភាពដល់ក្រុមប្រឹក្សាស្តីពីដំណើរវិវឌ្ឍន៍នៅកម្ពុជាចាប់តាំងពីខែឧសភាមក ដែលបានផ្តល់នូវដំណើរវិវឌ្ឍន៍សំខាន់ៗចាប់តាំងពីរបាយការណ៍លេខ A/HRC/36/61 ត្រូវបានដាក់ជូនមកក្រុមប្រឹក្សានេះ។

ដូចដែលបានកត់សម្គាល់នៅកថាខណ្ឌទី ៤៤ ដល់ ៤៩ ប្រទេសកម្ពុជាស្ថិតនៅក្នុងចន្លោះនៃការបោះឆ្នោត។ ការបោះឆ្នោតឃុំ/សង្កាត់ថ្នាក់មូលដ្ឋាន នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៧ ហាក់ដូចជាមានសណ្តាប់ធ្នាប់ល្អ និងមានភាពមិនប្រក្រតីមួយចំនួន ដែលទាមទារឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការដំណោះស្រាយ។ កម្មវិធីចុះឈ្មោះបោះឆ្នោតបានដំណើរការបានយ៉ាងល្អ ហើយមានប្រជាជនសរុបទាំងអស់ប្រហែល ៩០ ភាគរយ បានទៅបោះឆ្នោត។ នេះគឺជាភាពវិជ្ជមាន និងការលើកទឹកចិត្ត ដល់ការបោះឆ្នោតទូទៅដែលគ្រោងធ្វើនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៨។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពទូទៅដែលឈានទៅ និងក្រោយការបោះឆ្នោតឃុំ/សង្កាត់នេះ គឺគួរឲ្យព្រួយបារម្ភនៅក្នុងប្រទេសមួយដែលអះអាងថាជាប្រទេស

លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស (តាមរដ្ឋធម្មនុញ្ញ)។ មានការផ្លាស់ប្តូរយ៉ាងសំខាន់ពីរនៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ដែលការផ្លាស់ប្តូរមួយនៅក្នុងខែកុម្ភៈ ដែលបានអនុញ្ញាតឲ្យមានការរំលាយគណបក្សនយោបាយដោយមិនឲ្យមានការប្តឹងឧទ្ធរណ៍ ហើយការផ្លាស់ប្តូរមួយទៀតនៅក្នុងខែកក្កដា ដែលបានហាមឃាត់គណបក្សណាមួយមិនឲ្យប្រើសារសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាព របស់បុគ្គលដែលត្រូវបានផ្តន្ទាទោសពីបទបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម។ នៅក្នុងបរិបទកម្ពុជា ការធ្វើវិសោធនកម្មទាំងនេះប៉ះពាល់មិនសមមាត្រដល់តួអង្គគណបក្សប្រឆាំង។ នៅក្នុងការអនុវត្តជាក់ស្តែង ជោគវាសនារបស់គណបក្សប្រឆាំងហាក់ដូចជានៅក្នុងកណ្តាប់ដៃរបស់អង្គនីតិប្រតិបត្តិ។ ចាប់តាំងពីដើមខែសីហាមក ប្រធានរបស់បក្សប្រឆាំងចំនួនបី ត្រូវបានចាប់ឃុំខ្លួន។ វោហាសាស្រ្តហិង្សាជាទៀងទាត់របស់រដ្ឋមន្ត្រី និងមន្ត្រីយោធាជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល បង្កើតឲ្យមានការភ័យខ្លាច ដែលជារនាំងឧបសគ្គមួយដល់ការបោះឆ្នោតដោយសេរី។ វោហាសាស្រ្តទាំងនេះ គឺដូចគ្នានឹងវោហាសាស៍មុនៗធ្វើឡើងដោយភាគីផ្សេងទៀត ដែលញុះញង់ឲ្យមានការស្អប់ខ្ពើម។ **ដូចដែលខ្ញុំបានលើកឡើងពីមុនមកហើយ ពេលមានអំណាច អ្នកត្រូវប្រើប្រាស់វាឲ្យបានល្អជាគុណប្រយោជន៍សម្រាប់អ្នកដទៃ ហើយការគំរាមកំហែងជាទៀងទាត់ និងការបំភិតបំភ័យដើម្បីកេងចំណេញខាងនយោបាយមិនគួរមានសោះនៅក្នុងសង្គមសន្តិភាពដូចជាប្រទេសកម្ពុជា ដែលនៅតែមានស្លាកស្នាមនៃសោកនាដកម្មកាលពីអតីតកាលរបស់ខ្លួននៅឡើយ។**

កាលពីឆ្នាំមុន ខ្ញុំបានកត់សម្គាល់ (នៅកថាខណ្ឌទី ៨) ថា "ប្រសិនបើមិនមានកិច្ចខិតខំប្រឹងប្រែងផ្សះផ្សាពិតប្រាកដ ស្របតាមឆន្ទៈរបស់គណបក្សនយោបាយធំទាំងពីរ ដើម្បីបង្កើតឡើងវិញនូវវប្បធម៌សន្ទនាក្នុងបរិយាកាសគោរពគ្នាទៅវិញទៅមក នោះទេ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាអាចនឹងបន្តធ្លាក់ចុះទៀត នៅខែខាងមុខៗ។ ខណៈពេលដែលខ្ញុំកំពុងនិយាយនេះ ប្រធានគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា កំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន (តម្កល់ទុកដោយសាលាឧទ្ធរណ៍កាលពីម្សិលមិញ) លើបទសន្ទិដ្ឋិភាពជាមួយបរទេស ដែលជាទង្វើមួយសំដៅដល់ "ការបង្កអរិភាព ឬសកម្មភាព ឈ្លានពានប្រឆាំងនឹងកម្ពុជា"។ រដ្ឋាភិបាលបានពន្យល់ជាសាធារណៈថា សន្ទិដ្ឋិភាពនេះ កើតចេញពីសុន្ទរកថារបស់ ឯកឧត្តម កឹម សុខា នៅប្រទេសអូស្រ្តាលី កាលពីឆ្នាំ ២០១៣ ដែលអាចរកបានតាមអនឡាញ។ បើទោះជាយ៉ាងនេះក៏ដោយ គេអះអាងថាលោកត្រូវបានចាប់ខ្លួនពីបទល្មើសជាក់ស្តែង ដែលធ្វើដូច្នេះ ដើម្បីបញ្ចៀសដំណើរការនីតិវិធីធម្មតាក្នុងការដកអភ័យឯកសិទ្ធិសភា។ លោកត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ (មណ្ឌលអប់រំកែប្រែ **ម៣**) មុនពេលចោទប្រកាន់ និងបដិសេធសិទ្ធិស្របច្បាប់ជាច្រើនដែលមានចែងក្នុងច្បាប់កម្ពុជា រាប់ទាំង សិទ្ធិប្រាស្រ័យទាក់ទងជាសម្ងាត់ជាមួយមេធាវីរបស់លោក និងវត្តមានមេធាវីនៅក្នុងអំឡុងពេលសាកសួរដោយចៅក្រមស៊ើបអង្កេត។

**ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល សភា និងស្ថាប័នតុលាការ ឲ្យចាត់វិធានការដើម្បីធានាថា បទប្បញ្ញត្តិបទល្មើសជាក់ស្តែង ត្រូវបានប្រើតែនៅក្នុងស្ថានភាពដែលឆ្លើយតបទៅនឹងនិយមន័យធម្មតានៃពាក្យនោះប៉ុណ្ណោះ។ នេះគឺជាលើកទី ៤ ហើយ ក្នុងរយៈពេលពីរឆ្នាំ ដែលបទល្មើសជាក់ស្តែងនេះត្រូវបានប្រើដើម្បីចាប់ខ្លួនសមាជិកសភាគណបក្សប្រឆាំង។**

**ត្រូវមានការយកចិត្តទុកដាក់ឲ្យបានខ្លាំងដើម្បីធានាថា មានមូលដ្ឋានភ័ស្តុតាងរឹងមាំសម្រាប់ធ្វើការចោទប្រកាន់ណាមួយ។ នៅកថាខណ្ឌទី ៥៤ នៃរបាយការណ៍នេះ ខ្ញុំកត់សម្គាល់ថា បទដ្ឋានភ័ស្តុតាងខុសៗគ្នាស្រឡះ ត្រូវបានប្រើនៅតុលាការ ហើយខ្ញុំសូមអំពាវនាវម្តងហើយម្តងទៀត សូមឲ្យមានបទដ្ឋានបង្ហាញភ័ស្តុតាងដូចគ្នាសម្រាប់គ្រប់ករណី ហើយក៏សូមអំពាវនាវដល់ក្រសួងយុត្តិធម៌ឲ្យពិចារណាធ្វើសេចក្តីព្រាងសេចក្តីណែនាំស្តីពីលក្ខខណ្ឌតម្រូវភ័ស្តុតាង។**

មានសេចក្តីរាយការណ៍ថាមានការដាក់សម្ពាធទៅលើអង្គការក្រៅរដ្ឋាភិបាល ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ដោយមានការអនុវត្តនូវច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)។ អង្គការក្រៅរដ្ឋាភិបាលទាំងអស់ត្រូវបានតម្រូវឲ្យដាក់បញ្ជូនគណនីទៅក្រសួងមហាផ្ទៃនៅខែនេះ។ អង្គការជាច្រើនមានការព្រួយបារម្ភលើបញ្ហានេះ ចែករំលែកដោយសហជីពដែលដាក់បញ្ជូនគណនីទៅក្រសួងការងារ។ សកម្មភាពជាទៀងទាត់របស់អង្គការមិនមែនរដ្ឋាភិបាលក៏ទទួលរងផលប៉ះពាល់ផងដែរ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានបញ្ជាក់ប្រាប់ខ្ញុំកាលពីខែសីហាថា ឥឡូវនេះលោកតម្រូវឲ្យអង្គការសង្គមស៊ីវិលរាយការណ៍ពីសកម្មភាពទាំងអស់ដល់អាជ្ញាធរឃុំ និងស្រុក រាប់ទាំង សកម្មភាពអប់រំ/បណ្តុះបណ្តាល ផងដែរ។ ការធ្វើរបាយការណ៍បែបនេះមិនត្រូវបានតម្រូវដោយស្របច្បាប់ ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ទេ ហើយក៏ហាក់ដូចជាផ្ទុយនឹងច្បាប់កម្ពុជាស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ។ ទោះបីជារដ្ឋាភិបាលអះអាងថា ការធ្វើរបាយការណ៍នេះគឺដើម្បីធានាសុវត្ថិភាពបុគ្គលិកអង្គការ និងដើម្បីសម្របសម្រួលសកម្មភាពរបស់ពួកគេក៏ដោយ ក៏គេអាចយល់បានថា អង្គការក្រៅរដ្ឋាភិបាលចាត់ទុកថាបញ្ហានេះ ជាទម្រង់ត្រួតពិនិត្យ និងគ្រប់គ្រងដែលមានលក្ខណៈជ្រៀតជ្រែក។ ការអនុវត្តនូវបទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលអង្គការមិនមែនរដ្ឋាភិបាលត្រូវអព្យាក្រឹត្យខាងនយោបាយ កំពុងតែស្តែងឲ្យឃើញថាមានបញ្ហាហើយ នៅពេលដែលសកម្មភាពជាច្រើនដែលចាត់ទុកថាជាការរិះគន់រដ្ឋាភិបាល ត្រូវបានគេថាជារឿងនយោបាយ។ បទប្បញ្ញត្តិស្រដៀងគ្នានេះលេចឡើងនៅក្នុងច្បាប់សហជីពផងដែរ។ នៅក្នុងប្រទេសកម្ពុជានាសហសម័យនេះ អ្វីៗស្ទើរតែទាំងអស់អាចត្រូវបានគេចោទប្រកាន់ថាជារឿងនយោបាយ។ ការអំពាវនាវឲ្យមានការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យឥឡូវនេះ ត្រូវបានគេចាត់ទុកថាជាការបំភ័ន់ដើម្បីកេងចំណេញខាងនយោបាយ និងការវាយប្រហារដោយ

លំអៀងប្រឆាំងនឹងរដ្ឋាភិបាល។ **រដ្ឋាភិបាលគួរត្រលប់ទៅការពារ និងលើកទឹកចិត្តសង្គមស៊ីវិលដ៏រស់រវើក ដែលប្រទេសនេះត្រូវបានគេស្គាល់តាមរយៈនោះ និងកោតសរសើរដោយត្រឹមត្រូវ។ រាល់ការរឹតត្បិតលើ សកម្មភាពនានាគួរតែធ្វើឡើងនៅពេលចាំបាច់ អនុលោមតាមច្បាប់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ប៉ុណ្ណោះ។**

បញ្ហាពាក់ព័ន្ធមួយទៀត គឺការថយចុះយ៉ាងខ្លាំងក្នុងផ្នែកសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា។ ដោយចាប់ផ្តើមនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ភ្លាមៗបន្ទាប់ពីខ្ញុំបានបញ្ចប់បេសកកម្មរបស់ខ្ញុំ ស្ថានីយ៍វិទ្យុមួយចំនួនត្រូវបានបិទ ឬបានដាក់ការរឹតត្បិត។ វិទ្យុគឺជាប្រភពព័ត៌មានដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជាក៏ដូច្នេះជាការដាក់ការរិតត្បិតលើការផ្តល់អាជ្ញាប័ណ្ណ ឬការប្រើប្រាស់រលកធាតុអាកាសដែលកម្រិតមិនអាចជៀសផុតលើសេរីភាពរបស់ប្រជាជនកម្ពុជាក្នុងការទទួលបានព័ត៌មាន។ មុននេះ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ ២០១៧ កាសែតឌឹខេមបូឌាដេលី ត្រូវរងការវាយតម្លៃពន្ធឡើងវិញ ដែលបង្ហាញថាបំណុលពន្ធដារប្រមាណ ៦,៣ លានដុល្លារ អាមេរិក ត្រូវបង់ក្នុងរយៈពេល ៣០ ថ្ងៃ។ មិនមានដំណើរការត្រឹមត្រូវ ឬការចរចារត្រូវបាន អនុវត្តទេ អាជ្ញាប័ណ្ណកាសែតមិនត្រូវបានបន្ត ហើយកាសែតនេះបានបោះពុម្ពផ្សាយចុងក្រោយរបស់ខ្លួន នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ ដែលត្រូវធ្វើឲ្យបិទបញ្ចប់រយៈពេល ២៤ ឆ្នាំរបស់ខ្លួន ក្នុងការបោះពុម្ពផ្សាយកាសែតឯករាជ្យ។ **នៅក្នុងអំឡុងឆ្នាំបោះឆ្នោត មានការពិភាក្សា និងការរិះគន់ខាងនយោបាយ ក៏ដូចជាការ ទទួលបានប្រភពព័ត៌មានផ្សេងៗ មានសារៈសំខាន់ណាស់ដើម្បីធានាឲ្យអ្នកបោះឆ្នោតអាចយល់ច្បាស់អំពី គោលនយោបាយ និងគោលដៅរបស់អ្នកដែលគេត្រូវបោះឆ្នោតឲ្យ។**

ច្បាប់ជាច្រើនត្រូវបានគេប្រើប្រាស់ ដើម្បីរឹតត្បិតការរិះគន់រដ្ឋាភិបាល និងរារាំងការជជែកពិភាក្សានយោបាយនៅតែបន្តកើនឡើង។ ការចោទប្រកាន់ធ្ងន់ធ្ងរពីបទធ្វើអបគមន៍ ការបះបោរ ការក្លែងបន្លំ និងការក្បត់ជាតិ ត្រូវបានគេប្រើជាមួយនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការញុះញង់ ដែលទៅជារឿងធម្មតាទៅហើយ។ ផ្អែកលើភ័ស្តុតាងដែលមាន វាហាក់ត្រូវបានអនុវត្តដោយមិនស្របគ្នាក្នុងលក្ខណៈរើសអើង។ **មានគ្រោះថ្នាក់ជាច្រើន ដោយរដ្ឋមួយត្រូវបានគ្រប់គ្រងដោយច្បាប់ ច្រើនជាជាងគ្រប់គ្រងតាមបែបនីតិរដ្ឋ។**

រដ្ឋាភិបាល ចំពោះខ្លួនផ្ទាល់ បានបង្ហាញជាសាធារណៈពីកង្វល់របស់ខ្លួនអំពីអ្វីដែលខ្លួនចាត់ទុកថាជាយុទ្ធនាការផ្សព្វផ្សាយពត៌មានមិនពិត បំភ្លៃព្រឹត្តិការណ៍ និងការពិតជាប្រវត្តិសាស្ត្រ ដើម្បីបង្កើតរូបភាពអវិជ្ជមានរបស់ប្រទេសកម្ពុជា និងបន្ទោសរដ្ឋាភិបាល។ ជាការពិតណាស់ ឯកឧត្តម កែវ រ៉េមី ស្រាយពន្យល់អំពីទិដ្ឋភាពមួយចំនួននៃទស្សនៈរបស់រដ្ឋាភិបាលនៅក្នុងសេចក្តីថ្លែងការណ៍របស់លោក នៅឱកាសបើកសម័យប្រជុំក្រុមប្រឹក្សានេះ ហើយឯកឧត្តម ប្រាក់ សុខុន ក៏ធ្វើសេចក្តីថ្លែងការណ៍ដូចគ្នានេះដែរ នាមហាសន្និបាតនៅសប្តាហ៍មុន។ រដ្ឋមន្ត្រីមួយចំនួននៃរដ្ឋាភិបាលតែងតែបានរំលឹកប្រាប់ខ្ញុំអំពីភាពចាំបាច់នៃការរក្សាស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ទន្ទឹមនឹងនេះ ជាការពិត ការជជែកពិភាក្សានយោបាយ និងការរិះគន់ដល់គោលនយោបាយរបស់រដ្ឋាភិបាល (និងការជំទាស់) គឺជាផ្នែកធម្មតាមួយនៃសង្គមប្រជាធិបតេយ្យ។ ប៉ុន្តែការរឹតត្បិត

លំហប្រជាធិបតេយ្យ និងការធ្វើឲ្យអន្តរាយដល់ស្ថាប័នប្រជាធិបតេយ្យ បានឈានដល់កម្រិតដែលមិនធ្លាប់មានពីមុនមក ក្នុងប្រវត្តិសាស្ត្រក្រោយឆ្នាំ១៩៩៣។

លោកប្រធាន ឯកឧត្តម ក្នុងរបាយការណ៍របស់ខ្ញុំ បញ្ហាពន្ធនាគារដែលមានជនជាប់ឃុំច្រើនចង្អៀតណែនខ្លាំង ត្រូវបានកត់សម្គាល់នៅកថាខណ្ឌទី២៤។ ឆ្នាំនេះ ស្ថានភាពនេះកាន់តែធ្លាក់ចុះដល់កម្រិតគ្រោះថ្នាក់។ ដោយសារតែយុទ្ធនាការសកម្មរបស់រដ្ឋាភិបាលប្រឆាំងនឹងគ្រឿងញៀន ទើបមនុស្សប្រមាណជាមួយម៉ឺននាក់ត្រូវបានចាប់ខ្លួន និងឬឃុំខ្លួន។ មនុស្សជាច្រើននៅតែជាប់ឃុំក្នុងពន្ធនាគារនៅឡើយ ហើយខ្ញុំបានសង្កេតឃើញមានអនីតិជនត្រូវបានគេឃុំខ្លួន ក្នុងបន្ទប់ឃុំឃាំងជាមួយស្ត្រីពេញវ័យ។ មនុស្សផ្សេងទៀត ត្រូវបានឃុំខ្លួនក្នុងមជ្ឈមណ្ឌលសំចត ឬមជ្ឈមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀន។ ដោយសារតែពួកគេមិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីមជ្ឈមណ្ឌលទាំងនេះ ដែលទាំងនេះ បើតាមពាក្យពេចន៍សិទ្ធិមនុស្ស ហៅថាកន្លែងឃុំខ្លួន។ ដូចនេះ មានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីធានាថាការឃុំខ្លួនត្រូវបានត្រួតពិនិត្យឡើងវិញជាទៀងទាត់ស្របតាមច្បាប់ និងដោយមិនបំពាន។ ជាការពិតណាស់ វាក៏ចាំបាច់ឲ្យមានការឆ្លើយតបគ្រប់ជ្រុងជ្រោយទៅនឹងប្រព្រឹត្តកម្មលើពួកគេ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គម។

បើនិយាយពីមណ្ឌលឃុំខ្លួនវិញ ខ្ញុំគួរតែកត់សម្គាល់ផងដែរថានៅក្នុងខែសីហា ខ្ញុំត្រូវបានគេបដិសេធជាថ្មីម្តងទៀត មិនឲ្យជួបប្រជុំដោយសម្ងាត់ជាមួយជនជាប់ឃុំនៅក្នុងពន្ធនាគារចំនួនពីរ បើទោះជាខ្ញុំត្រូវបានអនុញ្ញាតឲ្យចូលមជ្ឈមណ្ឌលសំចត និងមជ្ឈមណ្ឌលស្តារនីតិសម្បទាក្តី។

លោកប្រធាន ឯកឧត្តម សូមងាកមកបណ្តឹងជាផ្លូវការនានាដែលបានផ្ញើទៅរដ្ឋាភិបាលកាលពីឆ្នាំមុន និងរបាយការណ៍របស់ស្ថាប័នសន្ធិសញ្ញា។ យោងតាមលេខជើងទំព័រទី៧ នៃរបាយការណ៍នេះ បុគ្គលិកបួនរូបរបស់អង្គការអាដហុក និងលេខាធិការរង គ.ជ.ប ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧។ **ទោះបីជា ខ្ញុំស្វាគមន៍ការដោះលែងឲ្យនៅក្រៅឃុំក្តី ដោយសារពួកគេត្រូវបានឃុំខ្លួនរយៈពេល ៤២៧ ថ្ងៃ ដោយមិនមានដំណើរវិវឌ្ឍន៍ជាដុំកំភួនក្នុងការបង្ហាញពីបទចោទប្រឆាំងនឹងពួកគេ ខ្ញុំសូមអំពាវនាវឲ្យទំលាក់ចោលការចោទប្រកាន់លើពួកគេជាស្ថាពរ តាមរយៈការលើកលែងចោទប្រកាន់ (មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។** វាគឺជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយគ្មានការពន្យារពេលហួសហេតុ ចំពោះការចោទប្រកាន់ដែលបន្តមានដោយគ្មានពេលកំណត់ និងហាក់ដូចជាត្រូវបានចាត់ការឡើងវិញដោយចេះៗនោះ។ ករណីរបស់សកម្មជន អ្នកស្រី ទេព វ៉ាន់នី ក៏ស្ថិតក្នុងចំណុចនេះដែរ - បច្ចុប្បន្ន អ្នកស្រី កំពុងជាប់ពន្ធនាគាររយៈពេលពីរឆ្នាំកន្លះហើយ (ត្រូវបានសាលាឧទ្ធរណ៍តម្កល់ទុកនៅខែសីហា ឆ្នាំ ២០១៧) ដោយចោទប្រកាន់ថាបានញុះញង់ឲ្យមានអំពើហិង្សា នៅក្នុងបាតុកម្មក្នុងឆ្នាំ២០១៣។ ជនណាមួយដែលត្រូវចាប់ខ្លួន និងចោទប្រកាន់ពីបទល្មើសមួយទៅតាមច្បាប់ មានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេលហួសហេតុ (មាត្រា ១៤ (៣) (គ) ICCPR)។ **ប្រសិនបើមិនមានភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីជំនុំជម្រះក្តីនោះទេ គួរតែត្រូវទម្លាក់ចោលការចោទប្រកាន់ ហើយលុបឈ្មោះចេញពីបញ្ជីចោទ ទោស។**

ខ្ញុំសូមស្វាគមន៍ការប្តេជ្ញាចិត្តដែលបានធ្វើឡើងក្នុងខែសីហា របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងនានា និងចូលរួមក្នុងកិច្ចសន្ទនាជាមួយនឹងនីតិវិធីពិសេសលើបញ្ហាទាំងឡាយដែលជាកង្វល់។ ខ្ញុំសូមស្វាគមន៍ផងដែរនូវការប្តេជ្ញាចិត្តរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាក្នុងការរៀបចំជាកាលវិភាគសម្រាប់ដាក់របាយការណ៍មួយចំនួនដែលបានហួសពេលកំណត់ត្រូវបញ្ជូនទៅស្ថាប័នសន្ធិសញ្ញា អ.ស.ប និងធ្វើផែនការសម្រាប់ដាក់បញ្ជូនឲ្យបានទាន់ពេលវេលានូវរបាយការណ៍បន្តបន្ទាប់ទៀត ។

បើទោះជាដូចបានលើកឡើងខាងលើនេះក្តី ក៏មានការវិវឌ្ឍជាវិជ្ជមានខ្លះដែរ លើបញ្ហាដែលបានលើកឡើងក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់ខ្ញុំ ដែលបានទាញចំណាប់អារម្មណ៍របស់ខ្ញុំនៅក្នុងខែសីហា។

ក្រសួងយុត្តិធម៌បានធ្វើបច្ចុប្បន្នភាពដល់ខ្ញុំ អំពីវិស័យមួយចំនួន ដែលក្នុងនោះដំណើរវិវឌ្ឍន៍ត្រូវបានគ្រោងទុក និងបានបញ្ជាក់ពីការបង្កើនថវិកា។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសជាអេឡិចត្រូនិច បាននិងកំពុងដាក់ឲ្យដំណើរការ ហើយក្រសួងកំពុងគ្រោងរៀបចំផងដែរនូវប្រព័ន្ធគ្រប់គ្រងសំណុំរឿងជាអេឡិចត្រូនិចជាលក្ខណៈទូលំទូលាយ។ បច្ចុប្បន្ននេះ ក៏នឹងមានការដាក់បង្ហាញរាល់ថ្លៃសេវាតុលាការ ហើយក៏មានការប្រើប្រាស់កាន់តែកើនឡើងថែមទៀត នូវទម្រង់ដីការឃុំខ្លួនបណ្តោះអាសន្ន។ ទាំងនេះ បង្ហាញពីសន្ទុះឆ្ពោះទៅរកតម្លាភាពកាន់តែច្រើននៅក្នុងប្រព័ន្ធយុត្តិធម៌។ ខ្ញុំក៏បានដឹងផងដែរ អំពីគម្រោងធ្វើការលើកកម្ពស់ការយល់ដឹងអំពីការត្រួតពិនិត្យមើលតាមផ្លូវតុលាការ ជាជម្រើសជំនួយឲ្យការឃុំខ្លួនបណ្តោះអាសន្ន គម្រោងសាកល្បងមួយដែលអាចមានស្តីពីការលើកកម្ពស់ទោសជំនួសឲ្យការឃុំខ្លួន និងគម្រោងសម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងករណីសមស្របមួយចំនួន។ ទោះបីជាខ្ញុំស្វាគមន៍ឆន្ទៈរបស់ក្រសួង ក្នុងការចាប់ផ្តើមអនុវត្តការងារលើកកម្ពស់ការយល់ដឹង និងចាប់ផ្តើមអនុវត្តកម្មវិធីសាកល្បងនេះក្តី ក៏មានប្រការគួរឲ្យកត់សម្គាល់ថាការគាំទ្ររបស់ការិយាល័យ OHCHR ប្រចាំកម្ពុជា ដែលលោករដ្ឋមន្ត្រីបានស្នើសុំសម្រាប់កម្មវិធីចំនួនពីរដំបូង ជាជាងការពឹងផ្អែកលើធនធានរបស់ក្រសួង។

ផែនការសម្រាប់ការពន្លឿនគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅតែកំពុងរៀបចំនៅឡើយ ហើយខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដទៃទៀតលើបញ្ហានេះ នៅក្នុងពេលប៉ុន្មានឆ្នាំខាងមុខនេះ។

ដូចដែលខ្ញុំបានកត់សម្គាល់នៅចុងបញ្ចប់នៃបេសកកម្មរបស់ខ្ញុំនៅក្នុងប្រទេសកម្ពុជាកាលពីខែមុន ប្រទេសនេះ ហាក់កំពុងផ្លាស់ប្តូរសន្សឹមៗឆ្ពោះទៅរកភាពប្រថុយប្រថានមួយ។ ដោយមានការប្តេជ្ញាចិត្តជាវិជ្ជមានចំពោះសិទ្ធិមនុស្ស ដូចដែលរដ្ឋមន្ត្រីនៃរដ្ឋាភិបាលជាច្រើនបានលើកឡើង នៅពេលដែលខ្ញុំបានជួបប្រជុំជាមួយពួកគាត់ក្នុងខែសីហាកន្លងទៅនេះ និងឆន្ទៈរបស់ពួកគាត់ក្នុងការទទួលស្គាល់បញ្ហាប្រឈមផ្សេងៗទើបខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ប្រទេសកម្ពុជានឹងដកថយពីមាត់ជ្រោះដែលប្រទេសនេះតែឈរលើ។ ខ្ញុំសន្យាថានឹងបន្តតាមដានស្ថានភាពរាប់ទាំងនៅក្នុងអំឡុងពេលបេសកកម្មរបស់ខ្ញុំលើកមុន និងនៅក្រោយការបោះឆ្នោត។ វាអាចថាមិនមានការគំរាមកំហែងនៃអំពើហិង្សា ការបង្ក្រាបការបះបោរ សង្គ្រាមស៊ីវិល ការញុះញង់ឲ្យមានការស្អប់ខ្ពើម ឬសេចក្តីថ្លែងការណ៍បែបអុចអាលឲ្យរើសអើងពូជសាសន៍ពីគណបក្ស

នយោបាយណាមួយឡើយ។ មានមនុស្សជាច្រើនបានធ្វើការដោយមិនខ្លាចញើយហត់នៅក្នុងជួររដ្ឋាភិបាល និងនៅក្រៅរដ្ឋាភិបាល ដើម្បីធានាឲ្យអន្តរកាលប្រព្រឹត្តទៅប្រកបដោយសន្តិភាពនៃប្រទេសកម្ពុជាពីជម្លោះ និងការប្រល័យពូជសាសន៍ទៅកាន់លទ្ធិប្រជាធិបតេយ្យស្របតាមរដ្ឋធម្មនុញ្ញ ដែលប្រទេសកម្ពុជានាសម័យទំនើបយកមកធ្វើជាមូលដ្ឋាន។ មាគ៌ានេះ ត្រូវតែបានបន្តទៅទៀត ហើយថាសមិទ្ធិផលក្នុងកិច្ចការពារសិទ្ធិមនុស្សដែលកម្ពុជាសម្រេចបានតាំងពីឆ្នាំ១៩៩៣ រហូតមក នឹងត្រូវបានរក្សាឲ្យនៅគង់វង្សមិនអន្តរាយឡើយ។ នេះគឺជាអ្វីដែលប្រជាជនកម្ពុជាទាំងអស់សមនឹងទទួលបាន។ ខ្ញុំសន្យាគាំទ្រដល់ប្រទេសកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងសូមអំពាវនាវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្ស និងរដ្ឋដទៃទៀត គាំទ្រដល់កម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។

ចប់